ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-May-2016, 08:00
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកជាភ័ស្តុតាង ឯកសារទាក់ទិននឹងសម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា នរោត្តម សីហនុ**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

ព្រុំ ផល្លា

Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI

ឌី សុជាតា

**ចម្លងជូន៖**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") ដាក់ការឆ្លើយតបនេះ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់លោក នួន ជា តាមវិធាន ៨៧(៤) សុំទទួលយកជាភ័ស្តុតាង ទាក់ទិននឹងសម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា នរោត្តម សីហនុ ("សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា")។

## II. សាវតារ

2. នៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើមួយ អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកចុតហ្មាយចំនួនបីច្បាប់ ខ្សែវីដេអូ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា ("សំណើ")[1]។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានផ្សព្វផ្សាយសំណៅចម្លងនៃសំណើនេះ និងឯកសារភ្ជាប់បន្ថែមទៅអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") និងភាគី មុនពេលជូនដំណឹងអំពីសំណើនេះជាផ្លូវការ តាមរយៈប្រព័ន្ធដាក់ឯកសារអេឡិចត្រូនិក ទៅភាគីនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៦[2]។

3. នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ លោក ខៀវ សំផន បានដាក់ការគាំទ្ររបស់គាត់ទៅនឹងសំណើ ("ការគាំទ្រ") ដោយមិនបានបន្ថែមទឡ្ហីករណ៍ថ្មីសំខាន់ទេ[3]។

4. នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦ ដែលជាកាលបរិច្ឆេទកំណត់ចុងក្រោយសម្រាប់ភាគីក្នុងការដាក់ចម្លើយតបទៅនឹងសំណើ សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីឆ្លើយ

[1] ឯកសារ **E396** "សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកចុតហ្មាយចំនួន បី ច្បាប់ ខ្សែវីដេអូ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមកោដ្ឋព្រះវររាជបិតា នរោត្តម សីហនុ" ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៦ ("សំណើ")។

[2] សារអេឡិចត្រូនិករបស់មេធាវីការពារក្តី ផ្ញើជូនមន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ (ឯកសារបន្ថែម ១)។

[3] ឯកសារ **E396/1** "ការគាំទ្ររបស់លោក ខៀវ សំផន ចំពោះ "សំណើ E396 របស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកចុតហ្មាយចំនួន បី ច្បាប់ ខ្សែវីដេអូ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមកោដ្ឋព្រះវររាជបិតា"" ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦។

តបទៅនឹងសំណើ និងការគាំទ្រ "ក្នុងចម្លើយតបរួមមួយ" ត្រឹមថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦[4]។ ទោះបីជាមេធាវីការពារក្តីជំទាស់ទៅនឹងសំណើនេះ ដែលធ្វើឲ្យសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេល ៤ ថ្ងៃក្នុងការដាក់ចម្លើយតបរបស់ខ្លួន ក្លាយជាសំណើដែលពុំមានយុត្តិកម្មក៏ដោយ[5] ក៏អង្គជំនុំជម្រះបានយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញា "ជាករណីលើកលែង" ដែរ[6]។

5. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើ និងការគាំទ្រ ("ចម្លើយតប")[7]។ ចម្លើយតបត្រូវបានជូនដំណឹងដល់ភាគី តាមរយៈប្រព័ន្ធដាក់ឯកសារអេឡិចត្រូនិក នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦។

## III. សារណាតប

### ក. ការចោទប្រកាន់ពីការបង្ខិតបង្ខំ និងភាពពាក់ព័ន្ធនៃភស្តុតាងដែលត្រូវបានស្នើឡើង

6. សហព្រះរាជអាជ្ញាបានជំទាស់ថា ភស្តុតាងដែលបានស្នើឡើងដោយមេធាវីការពារក្តីនៅក្នុងសំណើ ("ភស្តុតាងដែលបានស្នើឡើង") មិនប៉ះពាល់ដល់ភាពជឿជាក់បាននៃសក្ខីកម្មរបស់ Alexander Hinton ទេ ដោយសារមូលហេតុចំនួនពីរ។ ទីមួយ លោក Hinton មិនបានអះអាងថា សេចក្តីថ្លែងការណ៍របស់សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតាទៅកាន់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ("ក.ស.អ.ស.ប") នៅខែ មករា ឆ្នាំ ១៩៧៩ *ពិតជា* ធ្វើឡើងក្រោមការបង្ខិតបង្ខំទេ។ ទីពីរ លោក Hinton "ជំទាស់យ៉ាងខ្លាំង" ទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីដែលថា សេចក្តីថ្លែងការណ៍ទៅកាន់ ក.ស.អ.ស.ប ឆ្នាំ ១៩៧៩ ដូចគ្នាទៅនឹងសេចក្តីថ្លែងការណ៍នានារបស់

---

[4] សារអេឡិចត្រូនិកពីសហព្រះរាជអាជ្ញារងផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦ ("ឯកសារបន្ថែម ២")។

[5] សារអេឡិចត្រូនិកពីទីប្រឹក្សាច្បាប់របស់មេធាវីការពារក្តីផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦ ("ឯកសារបន្ថែម ៣")។

[6] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦ ("ឯកសារបន្ថែម ៤")។

[7] ឯកសារ **E396/2** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា និង ខៀវ សំផន សុំឲ្យទទួលយកភស្តុតាងអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងព្រះបរមរតនកោដ្ឋ សម្តេចឪ នរោត្តម សីហនុ" ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ("ចម្លើយតប")។

បក្សកុម្មុយនីស្តកម្ពុជា[8]។

7. ចំណុចទីមួយដែលសហព្រះរាជអាជ្ញាបានលើកឡើងគឺជាការបកស្រាយខុសចំពោះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី។ មេធាវីការពារក្តីយល់យ៉ាងច្បាស់ថា លោក Hinton ពុំអាចផ្តល់ភ័ស្តុតាង *អង្គហេតុ* ថាតើសេចក្តីថ្លែងការណ៍ទៅកាន់ ក.ស.អ.ស.ប ឆ្នាំ១៩៧៩ នោះ ស្ថិតក្រោមការបង្ខិតបង្ខំឬយ៉ាងណាទេ។ មេធាវីការពារក្តីក៏ពុំបានលើកឡើងថា លោក Hinton ពុំអាចឲ្យជឿជាក់បាន ដោយសារគាត់បានផ្តល់សក្ខីកម្មក្លែងពាក់ព័ន្ធនឹងអង្គហេតុនេះទេ។ អ្វីដែលមេធាវីការពារក្តីជំទាស់គឺថា ចំណុចខ្លះនៃ "ភ័ស្តុតាងជា*គំនិតយោបល់*"របស់លោក Hinton[9] មិនអាចជឿជាក់បាន ដោយសារភ័ស្តុតាងនេះមួយផ្នែកបានផ្អែកលើអង្គហេតុដែលមិនត្រឹមត្រូវ។ ជាពិសេស សេចក្តីសន្និដ្ឋានរបស់លោក Hinton ដែលថា សេចក្តីថ្លែងការណ៍ទៅកាន់ ក.ស.អ.ស.ប ឆ្នាំ១៩៧៩ មិនដូចគ្នាទៅនឹងសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដោយសារភាគច្រើន គាត់ជឿថា សេចក្តីថ្លែងការណ៍ទៅកាន់ ក.ស.អ.ស.ប ឆ្នាំ១៩៧៩ របស់សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា ត្រូវបានធ្វើឡើងក្រោមការបង្ខិតបង្ខំ[10]។ ហេតុនេះ ភ័ស្តុតាងដែលបង្ហាញថា សេចក្តីថ្លែងការណ៍ទៅកាន់ ក.ស.អ.ស.ប ឆ្នាំ១៩៧៩ បានឆ្លុះបញ្ចាំងពិតប្រាកដអំពីមតិយោបល់ពិតប្រាកដរបស់សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា នឹងធ្វើឲ្យប៉ះពាល់ដល់សេចក្តីសន្និដ្ឋានពីមុនរបស់លោក Hinton ហេតុនេះ វាធ្វើឲ្យមានការសង្ស័យទៅលើភាពជឿជាក់បាននៃភ័ស្តុតាងដែលជាគំនិតយោបល់របស់គាត់ទាក់ទិននឹងបញ្ហានេះ។

8. ចំណុចទីពីរដែលសហព្រះរាជអាជ្ញាបានលើកឡើងហួសឆ្ងាយពីការយល់ដឹងរបស់មេធាវីការពារក្តី។ សហព្រះរាជអាជ្ញាហាក់បីដូចជាលើកឡើងថា ដរាបណាសាក្សី "ជំទាស់ខ្លាំង" ទៅនឹងការលើកឡើងរបស់មេធាវីការពារក្តី ភ័ស្តុតាងដែលមេធាវីការពារក្តីដាក់ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលបដិសេធទៅនឹងភាពជឿជាក់បានរបស់សាក្សីនោះ នឹងធ្វើឲ្យភ័ស្តុតាង "ពុំមានតម្លៃ

---

[8] ឯកសារ **E396/2** ចម្លើយតប កថាខណ្ឌ ៥។

[9] ឯកសារ **E396** សំណើ កថាខណ្ឌ ១៨ (គូសបញ្ជាក់បន្ថែម)។

[10] *សូមមើល ឧទាហរណ៍* ប្រតិចារឹកសវនាការថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (Alexander Hinton ឯកសារ **E1/403.1**) ទំព័រ ១៩ បន្ទាត់ ៩ ដល់ ១៥ Hinton៖ "បើលោកមើលបរិបទនៃសុន្ទរកថាបែបនេះ គឺសុន្ទរកថារបស់កម្ពុជាប្រជាធិបតេយ្យ ហើយបើយើងប្រៀបធៀបជាមួយនឹងពាក្យដែលអតីតព្រះមហាក្សត្រប្រើប្រាស់ គឺក្រោយពេលកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ នៅពេលនោះ ព្រះអង្គក៏*ស្ថិតទៅក្រោមសម្ពាធ*របស់ខ្មែរក្រហមនៅឡើយដែរ។ យើងឃើញថាមានលក្ខណៈខុសគ្នាជាច្រើន" (គូសបញ្ជាក់បន្ថែម)។

ជាភ័ស្តុតាងទេ”[11]។ ចំណុចនេះផ្អែកពីសំអាងហេតុ ផ្អែកពីគោលការណ៍នីត្យានុកូលភាព និងផ្អែកពីសិទ្ធិរបស់ជនជាប់ចោទ។ ដូចដែលមេធាវីការពារក្តីបានលើកឡើងយ៉ាងច្បាស់នៅក្នុងសំណើគឺថា អង្គជំនុំជម្រះជាអ្នកសម្រេចចុងក្រោយនៅពេលបញ្ចប់ការជំនុំជម្រះ ដោយមានជំនួយពីភ័ស្តុតាងទាំងអស់ដែលមាននៅចំពោះមុខ រួមទាំងភ័ស្តុតាងថ្មីដែលមេធាវីការពារក្តីបានស្នើឡើងផងដែរ ថាតើអាចមានភាពស្របគ្នារវាងសេចក្តីថ្លែងការណ៍របស់សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា និងសេចក្តីថ្លែងការណ៍ជាក់លាក់របស់បក្សកុម្មុយនីស្តកម្ពុជា ឬយ៉ាងណា[12]។ វាជាការឆាប់រហ័សពេកដែលត្រូវប្រកាន់យកជំហរមួយណារវាងជំហររបស់សហព្រះរាជអាជ្ញា និងជំហររបស់មេធាវីការពារក្តី នៅក្នុងដំណាក់កាលទទួលយកភ័ស្តុតាងនេះ។

9. លើសពីនេះទៀត ភ័ស្តុតាងដែលទាក់ទិននឹងការបង្ខិតបង្ខំដែលបានចោទប្រកាន់នោះគឺអាចទទួលយកបាន ដោយមិនគិតអំពីភាពពាក់ព័ន្ធនៃភ័ស្តុតាងនោះទៅនឹងភាពគួរឲ្យជឿជាក់បាននៃភ័ស្តុតាងរបស់លោក Hinton ឡើយ។ អង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះអាចទទួលយកភ័ស្តុតាងដែល “ទាក់ទិនយ៉ាងជិតស្និទ្ធទៅនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង... ផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យវាយតម្លៃប្រភពទាំងនេះរួមគ្នា”[13]។ ភ័ស្តុតាងដែលបានស្នើឡើងដោយមេធាវីការពារក្តីនោះ ទាក់ទិនយ៉ាងជិតស្និទ្ធទៅនឹងភាពអាចទុកចិត្តបាននៃសេចក្តីថ្លែងការណ៍នៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៧៩ ដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយមេធាវីការពារក្តីស្នើសុំឲ្យផ្អែកទៅលើភ័ស្តុតាងនោះ។ មេធាវីការពារក្តីអះអាងថា ភ័ស្តុតាងដែលបានស្នើឡើង គួរតែទទួលយកផងដែរ ដោយផ្អែកទៅលើមូលដ្ឋាននេះ។

## ខ. បរិបទនៃភាសា និងភាពពាក់ព័ន្ធនៃភ័ស្តុតាងដែលបានស្នើឡើង

10. នៅក្នុងការដកស្រង់សក្ខីកម្មរបស់លោក Hinton ដែលថា បរិបទនៃភាសាមានសារៈសំខាន់នៅក្នុងការបកស្រាយអំពីភាពជាប់ពាក់ព័ន្ធ សហព្រះរាជអាជ្ញាអះអាងថា “ភ័ស្តុតាងដែលបាន

---

[11] ឯកសារ **E396/2** ចម្លើយតប កថាខណ្ឌ ៥ ដល់ ៦។

[12] ឯកសារ **E396** សំណើ កថាខណ្ឌ ១៨។

[13] ឯកសារ **E289/2** “សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភ័ស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)” ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។ *ស្របនឹង* ឯកសារ **E190** “សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត” ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣២។

ស្នើឡើងពុំមានតម្លៃភវនីយភាពអ្វីឡើយ នៅក្នុងការកំណត់ថាតើ ជនជាប់ចោទបានប្រើ ឬមិនបានប្រើពាក្យ "យួន" ដើម្បីញុះញង់ឲ្យមានការស្អប់ខ្ពើមជាតិសាសន៍ និងមានហិង្សាប្រឆាំងនឹងជនជាតិវៀតណាម ដោយសារ "បរិបទផ្សេងគ្នា គោលបំណង និងពេលវេលា ដែលអតីតសម្តេចឪបានថ្លែងសុន្ទរកថានោះ"[14]។

11. មេធាវីការពារក្តីមិនបានជំទាស់ថា ភាពជាប់ពាក់ព័ន្ធនៃការប្រើប្រាស់ភាសា ត្រូវតែបកស្រាយនៅក្នុងបរិបទនោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីជំទាស់ខ្លាំងទៅនឹងវិធីដែលលោក Hinton បកស្រាយបរិបទ ក៏ដូចជាសេចក្តីសន្និដ្ឋានរបស់គាត់ដែលបានផ្អែកទៅលើការបកស្រាយនេះ។ វាជាការមិនសមហេតុផលឡើយដែលលោក Hinton អះអាងចំណុចមួយថា ការប្រើប្រាស់ភាសាត្រូវតែបកស្រាយនៅក្នុងបរិបទនោះ ខណៈដែលចំណុចមួយទៀតបែរជាធ្វើការសន្និដ្ឋានជាទូទៅថា ការប្រើប្រាស់ពាក្យ "យួន" នៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ *គឺជា* ការញុះញង់ឲ្យមានអំពើប្រល័យពូជសាសន៍"[15]។ ការចាត់ទុកកម្ពុជាប្រជាធិបតេយ្យជា "បរិបទ" មួយដោយមិនបានពិនិត្យមើលទៅលើកាលៈទេសៈជាក់លាក់ (បរិបទជាក់លាក់) នៃគ្រប់សេចក្តីថ្លែងការណ៍ទាំងអស់ដែលបានធ្វើឡើងដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះ ពុំមានភាពខុសគ្នាឡើយ ពាក់ព័ន្ធនឹងភាពមិនសមហេតុផលក្នុងការអះអាងថា គ្រប់សមាជិកនៃក្រុមពូជសាសន៍មួយគឺអន់ជាងសមាជិកនៃក្រុមពូជសាសន៍មួយផ្សេងទៀត។ មេធាវីការពារក្តីជំទាស់ទៅនឹងវិធីសាស្ត្រ និងសេចក្តីសន្និដ្ឋានរបស់លោក Hinton ដោយស្នើសុំឲ្យអង្គជំនុំជម្រះ*ក្នុងចំណោមប្រការផ្សេងៗទៀត* ទទួលយក និងពិចារណាលើសុន្ទរកថារបស់សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា ដែលមេធាវីការពារក្តីលើកឡើងថាដូចគ្នាជាមួយនឹងសេចក្តីថ្លែងការណ៍មួយចំនួនរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ ភាពដូចគ្នានោះ *ក្នុងចំណោមប្រការផ្សេងទៀត* គឺថា ទាំងសម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា និងទាំងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មានក្តីព្រួយបារម្ភអំពីមហិច្ឆតារបស់វៀតណាមក្នុងការលេបទឹកដីកម្ពុជា និងបានព្រមានដល់ប្រជាជនកម្ពុជាអំពីការគំរាមកំហែង និងគ្រោះថ្នាក់ពីសំណាក់ "យួន"។

12. បញ្ហាថាតើអាចធ្វើការប្រៀបធៀបបាន ឬក៏អត់ ដែលនេះទំនងជាបញ្ហាចម្រូងចម្រាសមួយ ដោយ

[14] ឯកសារ **E396/2** ចម្លើយតប កថាខណ្ឌ ៧-៨។

[15] ប្រតិចារឹក ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ (Alexander Hinton ឯកសារ **E1/404.1**) ទំព័រ (ភាសាអង់គ្លេស) ៨៣ បន្ទាត់ ៧-១០ (សេចក្តីបញ្ជាក់បន្ថែម)។

សារតែសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីជំទាស់យ៉ាងខ្លាំងក្លានោះ គឺទុកឱ្យអង្គជំនុំជម្រះធ្វើការសម្រេចនៅពេលបញ្ចប់ការជំនុំជម្រះ ដោយសំអាងលើភស្តុតាងទាំងអស់ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ។ វាជាការឆាប់រហ័សពេក និងជាវិការៈផ្លូវច្បាប់ ក្នុងការស្នើសុំឱ្យអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចរបស់ខ្លួនទៅលើបញ្ហានេះ នៅក្នុងដំណាក់កាលទទួលយកភស្តុតាង ចុះទម្រាំតែប្រើប្រាស់សេចក្តីសម្រេចបែបនេះក្នុងការបដិសេធភស្តុតាងទៀតនោះ។

13. ដូច្នេះ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា ភស្តុតាងដែលស្នើឡើងនោះ មិនអាចទទួលយកបាន ដោយសារតែសុន្ទរកថាទាំងនោះរបស់សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតា ធ្វើឡើងនៅក្នុងបរិបទផ្សេងគ្នា និងមានគោលបំណងផ្សេងគ្នា ដែលចំណុចនេះមេធាវីការពារក្តីមិនយល់ស្របទាល់តែសោះនោះ ពុំមានមូលដ្ឋានអ្វីឡើយ។

## គ. ភាពជាប់ទាក់ទិននៃភស្តុតាងនៃអំពើរបស់ភាគីទីបី

14. សហព្រះរាជអាជ្ញាអះអាងថា បញ្ហាថាតើ សុន្ទរកថារបស់សម្តេចព្រះបរមរតនកោដ្ឋព្រះវររាជបិតាបានប្រើប្រាស់ភាសាប្រកាន់ពូជសាសន៍ មិនពាក់ព័ន្ធទៅនឹងការកំណត់បទចោទនានាប្រឆាំងនឹងជនជាប់ចោទទេ[16]។

15. វាជាការមិនសមហេតុផលទាល់តែសោះដែលសហព្រះរាជអាជ្ញាអះអាងថា ភស្តុតាងបែបនេះមិនជាប់ពាក់ព័ន្ធទេ នៅពេលដែលសហព្រះរាជអាជ្ញាគឺជាអ្នកដែលបានលើកបង្ហាញភស្តុតាងដែលជាមតិយោបល់របស់ លោក Hinton ដែលភាគច្រើនផ្អែកទៅលើភាព ដូចគ្នាដែលគាត់បានកំណត់រវាងអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងរបបណាហ្ស៊ីអាល្លឺម៉ង់ និងរវ៉ាន់ដា ព្រមទាំងរវាងភាសាដែលកម្ពុជាប្រជាធិបតេយ្យបានប្រើ និងភាសាដែលពួកណាហ្ស៊ីអាល្លឺម៉ង់ និងរវ៉ាន់ដាបានប្រើនៅក្នុងការឃោសនាប្រល័យពូជសាសន៍របស់ពួកគេ[17]។

16. ភស្តុតាងនៃអំពើរបស់ភាគីទីបី ជាទូទៅ មិនជាប់ពាក់ព័ន្ធឡើយនៅក្នុងរឿងក្តីធម្មតា។ ប៉ុន្តែ នៅ

---

[16] ឯកសារ **E396/2** ចម្លើយតប កថាខណ្ឌ ៨។

[17] សូមមើល ឧទា. ប្រតិចារឹក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ (Alexander Hinton ឯកសារ **E1/401.1**) ទំព័រ (ភាសាអង់គ្លេស) ៤០ បន្ទាត់ ២, ទំព័រ ៦៣ បន្ទាត់ ៣-២០ និងទំព័រ ៩២ បន្ទាត់ ២១ - ទំព័រ ៩៣ បន្ទាត់ ៦។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (Alexander Hinton ឯកសារ **E1/403.1**) ទំព័រ ១១២ បន្ទាត់ ១៨ - ទំព័រ ១១៣ បន្ទាត់ ១៣។

ពេលសាក្សីជំនាញប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបដើម្បីឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានរបស់គាត់នោះ ជនជាប់ចោទមានសិទ្ធិធ្វើការប្រៀបធៀបស្រដៀងគ្នានេះដែរ ក្នុងគោលបំណងដើម្បីវាយតម្លៃអំពីភាពជឿទុកចិត្តបាននៃវិធីសាស្ត្រ និងសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញរូបនោះ។ នេះគឺជាអ្វីដែលមេធាវីការពារក្តីស្នើសុំនោះ។

## IV. **សំណូមពរ**

17. យោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញានៅក្នុងចម្លើយតប និងទទួលយកឯកសារដែលមេធាវីការពារក្តីបានស្នើឡើងនៅក្នុងសំណើរបស់ខ្លួន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងធ្វើជាភស្តុតាង។

**សហមេធាវីការពារក្តីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**